# មេរៀនសង្ខេប

- អង់ស៊ីមជាកាតាលីករជីវៈ ដែលជំរុញល្បឿនប្រតិកម្មគីមីផ្សេងៗ ។ គ្រប់សកម្មភាពទាំងអស់ នៅក្នុងសារពាង្គកាយ មិនអាចប្រព្រឹត្តទៅបានទេប្រសិនបើគ្មានអង់ស៊ីម។ អង់ស៊ីមជាកាតាលីករជីវៈដែលមានប្រតិកម្មយថាប្រភេទកម្រិតខ្ពស់។ សកម្មភាពរបស់វាទៀងទាត់និង ជាក់លាក់ ។ អង់ស៊ីមទាំងអស់សុទ្ធតែជាប្រូតេអ៊ីន។
- សព្វថ្ងៃនេះ គេធ្វើចំណែកថ្នាក់និងដាក់ឈ្មោះអង់ស៊ីម ដោយផ្អែកលើនាទីរបស់វា។ ឈ្មោះរបស់អង់ស៊ីមតែងបញ្ចប់ដោយពាក្យ " អាស" (-ase)បន្ថែមទៅលើឈ្មោះស៊ុបស្ត្រាត ។
- អង់ស៊ីមជាប្រូតេអ៊ីនដែលមានសកម្មភាពខ្លាំងក្លាបំផុត។អង់ស៊ីមមួយចំនួនតូចអាចបង្កើនល្បឿនប្រតិកម្មគីមីបានមួយភាគធំ។ វាអាចបង្កើនល្បឿនប្រតិកម្មគីមីផ្សេងៗ។ អង់ស៊ីមខ្លះ៖ អាចបំបែកស៊ុបស្ត្រាត រាប់លានម៉ូលេគុលតែក្នុងមួយវិនាទី។ អង់ស៊ីមមួយមានអំពើតែទៅលើ ស៊ុបស្ត្រាតមួយ ។ វាជាប្រូតេអ៊ីនយថាប្រភេទ ។
  អង់ស៊ីមមានដំណើរការប្រសើរបំផុតនៅពេលសីតុណ្ហភាពខ្ពស់។កាលណាសីតុណ្ហភាពខ្ពស់ពេកឬទាបពេកអង់ស៊ីមនិងបាត់បង់គុណភាព ។ នៅពេលមានសូលុយស្យុងបាសខ្លាំងឬអាស៊ីតខ្លាំង ក៏អាចធ្វើឱ្យអង់ស៊ីមបាត់បង់គុណភាពដែរ។
- ម្យ៉ាងទៀត កាលណាកំហាប់ស៊ុបស្ត្រាតឬកំហាប់អង់ស៊ីមកាន់តែខាប់ ល្បឿនប្រតិកម្មគីមី កាន់តែលឿនឡើង ។ នៅពេលខ្លះ៖ អង់ស៊ីមក៏ត្រូវការកូអង់ស៊ីម ដើម្បីជួយក្នុងប្រតិកម្មគីមីដែរ ។ កូអង់ស៊ីមភាគច្រើនជាវីតាមីន(ឬជីវជាតិ) ។ សកម្មភាពរបស់អង់ស៊ីមក្នុងប្រតិកម្មភាគ ច្រើនសុទ្ធតែជាប្រតិកម្មបញ្ច្រាស ។